**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
លេខ: ៧៣៩ សជណ.ចល

# សេចក្តីជូនដំណឹង

## ស្តីពីការចាក់វ៉ាក់សាំងកូវីដ-១៩ (Sinovac) ជូសទី២ ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យានៃទីស្តីការគណៈរដ្ឋមន្ត្រី នៅមន្ទីរពេទ្យកាល់ម៉ែត ចាប់ពីថ្ងៃទី១៩ ដល់ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២១

អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ នៅទីស្តីការគណៈរដ្ឋមន្ត្រី សូមជម្រាបឯកឧត្តម លោកជំទាវ លោក លោកស្រីជាថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាទាំងអស់នៃទីស្តីការគណៈរដ្ឋមន្ត្រីមេត្តាជ្រាបថា ដោយមានសំណូមពរជាថ្មីពីផ្នែកទទួលបន្ទុកការចាក់វ៉ាក់សាំងកូវីដ-១៩ នៃមន្ទីរពេទ្យកាល់ម៉ែត តារាងកាលវិភាគត្រូវបានកែសម្រួលដូចមានក្នុងតារាងជូនភ្ជាប់មកជាមួយ។

ទន្ទឹមនឹងនេះ អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ នៅទីស្តីការគណៈរដ្ឋមន្ត្រី សូមធ្វើការណែនាំដូចខាងក្រោម៖

១- ត្រូវយកទៅជាមួយនូវប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ (**ចាក់លើកទី១**) និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

២- ត្រូវពាក់អាវដៃខ្លីនៅពេលចាក់វ៉ាក់សាំង (**សម្លៀកបំពាក់សមរម្យ**)

៣- អង្គភាព និងអគ្គនាយកដ្ឋានដែលមានឈ្មោះនៅក្នុងតារាងបែងចែក ត្រូវចាត់តំណាងដើម្បីត្រួតពិនិត្យសម្របសម្រួល និងរៀបចំរបាយការណ៍លទ្ធផលនៃការចាក់វ៉ាក់សាំង រួចផ្តល់ទៅលោក **ពៅ ចាន់បុផល** (**ទូរសព្ទលេខ ០១២ ៤៩០ ០០១**) យ៉ាងយូរត្រឹមមួយម៉ោង ក្រោយពីការចាក់វ៉ាក់សាំងរបស់អង្គភាព និងអគ្គនាយកដ្ឋាននីមួយៗរួចរាល់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោកជំទាវ លោក លោកស្រីជាថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាទាំងអស់អនុវត្តតាមការជូនដំណឹងខាងលើឱ្យបានប្រកបដោយប្រសិទ្ធភាពខ្ពស់។ ៚

ថ្ងៃព្រហស្បតិ៍ ៤កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១

# ទីស្តីការគណៈរដ្ឋមន្ត្រី
គណៈកម្មការចាក់វ៉ាក់សាំងកូវីដ-១៩

## កាលវិភាគនៃការចាក់វ៉ាក់សាំងកូវីដ-១៩ (Sinovac) ដូសទី២
## ចាប់ពីថ្ងៃចន្ទ ទី១៩ ដល់ថ្ងៃពុធ ទី២១ ខែមេសា ឆ្នាំ២០២១ នៅមន្ទីរពេទ្យកាល់ម៉ែត

| ល.រ | ឈ្មោះអង្គភាព |
|---|---|
| | ថ្ងៃទីចន្ទ ទី១៩ ចាប់ផ្តើមពីម៉ោង ៨:៣០ នាទីព្រឹក ដល់ម៉ោង ១១:៣០ នាទី |
| ១ | **ថ្នាក់ដឹកនាំ** |
| ២ | **ទីប្រឹក្សារាជរដ្ឋាភិបាល** |
| ៣ | **ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី** |
| ៤ | **ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី** |
| ៥ | **ទីប្រឹក្សា និងជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី** |
| ៦ | **ជំនួយការឯកឧត្តមទេសរដ្ឋមន្ត្រី** |
| ៧ | **ជំនួយការឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី** |
| ៨ | **ជំនួយការរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងបុគ្គលិកស្ម័គ្រចិត្ត** |
| ៩ | **អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ** |
| ៩.១ | នាយកដ្ឋានរដ្ឋបាល |
| ៩.២ | នាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញវត្ថុ |
| ៩.៣ | នាយកដ្ឋានបុគ្គលិក |
| ៩.៤ | នាយកដ្ឋានពិធីការ |
| ១០ | **អគ្គនាយកដ្ឋានសម្របសម្រួលកិច្ចការទូទៅ** |
| ១០.១ | នាយកដ្ឋានរៀបចំកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនិងកិច្ចប្រជុំផ្សេងទៀត |
| ១០.២ | នាយកដ្ឋានស្រាវជ្រាវនិងរៀបចំឯកសារគាំទ្រកិច្ចប្រជុំ |
| ១០.៣ | នាយកដ្ឋានឯកសារអេឡិចត្រូនិចនិងព័ត៌មានវិទ្យា |
| ១០.៤ | នាយកដ្ឋានសរុប |
| ១០.៥ | នាយកដ្ឋានឥស្សរិយយស |

| | |
|---|---|
| **ថ្ងៃទីចន្ទ ទី១៩ ចាប់ផ្ដើមពីម៉ោង ២:០០ នាទីរសៀល ដល់ម៉ោង ៣:៣០ នាទីរសៀល** | |
| ១១ | **អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ** |
| ១១.១ | នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ |
| ១១.២ | នាយកដ្ឋានអាស៊ាន |
| ១២ | **អគ្គនាយកដ្ឋានសម្របសម្រួលកិច្ចការផ្ទៃក្នុង** |
| ១២.១ | នាយកដ្ឋានមហាផ្ទៃ ការពារជាតិ យុត្តិធម៌ និងស្ថាប័នធម្មនុញ្ញ |
| ១២.២ | នាយកដ្ឋានមុខងារសាធារណៈ និងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច |
| ១២.៣ | នាយកដ្ឋានព័ត៌មាន ប្រៃសណីយ៍ និងទូរគមនាគមន៍ |
| ១៣ | **អគ្គនាយកដ្ឋានសេដ្ឋកិច្ចនិងទេសចរណ៍** |
| ១៣.១ | នាយកដ្ឋានហិរញ្ញវត្ថុនិងធនាគារ |
| ១៣.២ | នាយកដ្ឋានឧស្សាហកម្ម សិប្បកម្ម រ៉ែ និងថាមពល |
| ១៣.៣ | នាយកដ្ឋានពាណិជ្ជកម្មនិងទេសចរណ៍ |
| ១៣.៤ | នាយកដ្ឋានផែនការនិងអភិវឌ្ឍន៍ |
| ១៤ | **អគ្គនាយកដ្ឋានកិច្ចការសង្គម** |
| ១៤.១ | នាយកដ្ឋានអប់រំ ការងារ វប្បធម៌ ធម្មការ និងសាសនា |
| ១៤.២ | នាយកដ្ឋានសុខាភិបាល សង្គមកិច្ច និងកិច្ចការនារី |
| ១៥ | **អគ្គនាយកដ្ឋានផលិតកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់** |
| ១៥.១ | នាយកដ្ឋានកសិកម្មនិងធនធានទឹក |
| ១៥.២ | នាយកដ្ឋានអភិវឌ្ឍន៍ជនបទ សាធារណការ និងដឹកជញ្ជូន |
| ១៥.៣ | នាយកដ្ឋានរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងបរិស្ថាន |
| ១៦ | **អគ្គនាយកដ្ឋានរាជកិច្ច និងតម្កល់ឯកសារជាតិ** |
| ១៦.១ | នាយកដ្ឋានរាជកិច្ច |
| ១៦.២ | នាយកដ្ឋានតម្កល់ឯកសារជាតិ |
| **ថ្ងៃទីអង្គារ ទី២០ ចាប់ផ្ដើមពីម៉ោង ៨:៣០ នាទីព្រឹក ដល់ម៉ោង ១១:៣០ នាទីព្រឹក** | |
| ១៧ | នាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ១៨ | មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា |
| ១៩ | រាជបណ្ឌិត្យសភាកម្ពុជា |
| ២០ | ក្រុមមេធាវីស្ម័គ្រចិត្តសម្ដេចតេជោសែន |
| ២១ | ក្រុមប្រឹក្សាអ្នកច្បាប់ |

| | |
|---|---|
| **ថ្ងៃទីអង្គារ ទី២០ ចាប់ផ្ដើមពីម៉ោង ២:០០ នាទីរសៀល ដល់ម៉ោង ៣:៣០ នាទីរសៀល** | |
| ២២ | ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ |
| ២៣ | ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ |
| ២៤ | គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយ ផលិតផលមួយ |
| ២៥ | អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន |
| ២៦ | គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ |
| ២៧ | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| **ថ្ងៃទីពុធ ទី២១ ចាប់ផ្ដើមពីម៉ោង ៨:៣០ នាទីព្រឹក ដល់ម៉ោង ១១:៣០ នាទីព្រឹក** | |
| ២៨ | លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន |
| ២៩ | គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា |
| ៣០ | អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស |
| ៣១ | វេទិកាសម្ព័ន្ធសង្គមស៊ីវិល |
| ៣២ | អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល |
| **ថ្ងៃទីពុធ ទី២១ ចាប់ផ្ដើមពីម៉ោង ២:០០ នាទីរសៀល ដល់ម៉ោង ៣:៣០ នាទីរសៀល** | |
| ៣៣ | លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម |